# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## សហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រេនឌ៍អង្គរ
## និង
## ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រេនឌ៍អង្គរ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី១៩ ខែឧសភា ឆ្នាំ២០២១ រវាងសហជីពកម្មករ និយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រេនឌ៍អង្គរ (ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រេនឌ៍អង្គរ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Grand Hotel d'Angkor កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃជំងឺកូរ៉ូណាវីរុស ទូទាំងពិភពលោកបានបណ្តាលឱ្យសណ្ឋាគារត្រូវបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចា និងព្រមព្រៀង លើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២១នាក់ (ស្រី ៣៧នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២១២នាក់ (ស្រី ៧៥នាក់) រយៈពេល ២៨ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

គូភាគីទាំងពីរព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

និយោជិតដែលត្រូវបានព្យួរការងារជាបណ្តោះអាសន្ននឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- និយោជិតនឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ឈ្នួលគោលប្រចាំខែ ក្នុងអំឡុងពេលនៃការព្យួរការងារ។
- និយោជិតនឹងទទួលបាន**អង្ករ ១០ គីឡូក្រាម និង ត្រីខ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ នឹងបន្តក្នុងកំឡុងការព្យួរការងារ។
- អតីតភាពការងារនឹងមិនទទួលរងផលប៉ះពាល់។

សណ្ឋាគារនឹងតម្រូវឱ្យនិយោជិតមួយចំនួនបន្តធ្វើការពេញម៉ោងក្នុងអំឡុងពេលនៃការផ្អាកប្រតិបត្តិការនេះ ដើម្បីថែទាំសណ្ឋាគារ។

- និយោជិតទាំងនេះនឹងទទួលបានប្រាក់ឈ្នួល ១០០%។
- និយោជិតដែលបំពេញការងារក្នុងអំឡុងពេលផ្អាកប្រតិបត្តិការសណ្ឋាគារនឹងទទួលបានប្រាក់ឧបត្ថម្ភធ្វើដំណើរបន្ថែមចំនួន ៣០ ដុល្លារ ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ ដូចជាការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រនឹងនៅតែមានជាធម្មតា។
- និយោជិតដែលបំពេញភារកិច្ចនឹងទទួលបានអាហារជាធម្មតា។
- និយោជិតទាំងនេះអាចនឹងត្រូវបានស្នើសុំឱ្យបំពេញការងារក្រៅកាតព្វកិច្ចធម្មតារបស់ខ្លួន។ ប៉ុន្តែ ការបណ្តុះបណ្តាលដែលសមរម្យនឹងត្រូវបានផ្តល់ដើម្បីធានាថាកិច្ចការអាចត្រូវបានបញ្ចប់ដោយសុវត្ថិភាព (ឧទាហរណ៍៖ បុគ្គលិកផ្នែកម្ហូបអាហារនិងភេសជ្ជៈធ្វើការសំអាតអាងទឹក)។ ក្នុងករណីមានការកក់សណ្ឋាគារជាក្រុមភ្លាមៗក្នុងកំឡុងពេលផ្អាក

Raffles Grand Hotel Pte., Ltd.

- ប្រតិបត្តិការ និយោជិតមួយចំនួនឬទាំងអស់ អាចត្រូវបានគេតម្រូវឱ្យមកធ្វើការ។ និយោជិតនឹងទទួលបាន ប្រាក់ឈ្នួល ១០០%នៃប្រាក់ឈ្នួលប្រចាំថ្ងៃធម្មតារបស់ពួកគេ (ដោយមិនមានប្រាក់ឧបត្ថម្ភសំរាប់ការធ្វើដំណើរ) ខណៈប្រាក់ជានានុគ្រោះត្រូវបានផ្តល់ជូនសំរាប់និយោជិកដែលបានបំពេញភារកិច្ច។

នៅពេលស្ថានភាពជំងឺ Covid-19 មានភាពប្រសើរឡើងវិញ និយោជកនឹងមានកាតព្វកិច្ចទាក់ទងនិយោជិតគ្រប់ៗគ្នាដើម្បីវិលត្រឡប់មកធ្វើការងារដូចធម្មតាវិញ ហើយអត្ថប្រយោជន៍ដែលមាននៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួមនឹងត្រូវរក្សានៅដំដែល។

គូភាគីព្រមព្រៀងលើកិច្ចព្រមព្រៀងនេះដោយចុះហត្ថលេខាខាងក្រោមនេះ៖

ចុះហត្ថលេខាតាងនាមភាគីនិយោជក

សៀមរាប ថ្ងៃទី 19 ខែ 05 ឆ្នាំ២០២១
ហត្ថលេខា និងត្រា
នាយកសណ្ឋាគារ

Raffles Grand Hotel Pte. Ltd.

Dennis de Groot

ចុះហត្ថលេខាតាងនាមភាគីសហជីព

រស់ ប៊ុនណាល់
ប្រធានសហជីព

វ៉េង ភីរុត
អនុប្រធានសហជីព

សៅ វណ្ណដា
លេខាធិការសហជីព

ប៉ាត សំបូរ
ប្រធានកិត្តិយសសហជីព